# ធនាគារជាតិ នៃ កម្ពុជា

## ព្រឹត្តិបត្រប្រចាំត្រីមាស



## លេខ ២៤

## ត្រីមាសទី២ ឆ្នាំ២០០៨

ចេញផ្សាយតាមប្រកាសលេខ ធ១-០២-១២៦ ប្រ.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២

បោះពុម្ពផ្សាយដោយ

## ធនាគារជាតិ នៃ កម្ពុជា

អាសយដ្ឋាន ២២-២៤ មហាវិថីព្រះនរោត្តម
ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រ ២៥

ទូរស័ព្ទ (៨៥៥) ២៣ ៧២២ ៥៦៣

ទូរសារ (៨៥៥) ២៣ ៤២៦ ១១៧

គេហទំព័រ www.nbc.org.kh/khmer/

*********

*Published by*

## National Bank of Cambodia

**Address : 22-24 Preah Norodom Blvd.**
**Phnom Penh – Cambodia**

**P.O.BOX : 25**

**Phone : (855) 23 722 563**

**FAX : (855) 23 426 117**

**Website : www.nbc.org.kh/khmer/**



| គណៈ កម្មការព្រឹត្តិបត្រ | | Review Commission | |
|---|---|---|---|
| - ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| - ឯកឧត្តម បណ្ឌិត ស៊ុំ សន្និសិដ្ឋ | និពន្ធនាយក | H.E. Dr. Sum Sannisith | Chief Editor |




**ប្រិយមិត្តអ្នកអាន ជាទីមេត្រី !**

ព្រមពេលដែលសេដ្ឋកិច្ចកម្ពុជាបន្តកើនឡើង ១០,១% ក្នុងឆ្នាំ២០០៧ បញ្ហាប្រឈមអំពីទំនិញឡើងថ្លៃ បានបង្ខំឱ្យមានការស្វះស្វែងរកវិធានការទប់ស្កាត់ពីសំណាក់អាជ្ញាធរសាធារណៈ ជាពិសេស នៅក្នុងត្រីមាសទី១ ឆ្នាំ២០០៨ តាមការគណនាថ្មី សន្ទស្សន៍ថ្លៃទំនិញបានកើន (២៣,៤៧%) ធៀបនឹង (៥,៧២%) ក្នុងត្រីមាសទី១ ឆ្នាំ២០០៧ ។

និន្នាការអតិផរណាខ្ពស់ ឆ្នាំ២០០៨ ពុំមែនជាបញ្ហាដោយឡែករបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាជាបញ្ហាប្រឈមទូទៅក្នុងសកលលោក ជាពិសេសនៅក្នុងចំណោមបណ្តាប្រទេសក្រីក្រនិងប្រទេសកំពុងអភិវឌ្ឍ ឧទាហរណ៍ នៅប្រទេសថៃ ប្រភេទអង្ករស្តង់ដារពិភពលោក បានកើនដល់៩៥០ដុល្លារអាមេរិក ក្នុងមួយតោន គឺបានកើន៣ដងធៀបនឹងដើមឆ្នាំ២០០៧ ។ ការកើនឡើងថ្លៃអង្ករដែលពុំធ្លាប់ជួបប្រទះពីមុនមកនេះ ត្រូវបានអ្នកវិភាគសន្និដ្ឋានថា បើនៅតែបន្តទៀត នឹងចោទជាការគំរាមកំហែងដល់រដ្ឋាភិបាលនៃប្រទេសក្នុងតំបន់ អំពីអស្ថិរភាពសេដ្ឋកិច្ចនិងសង្គម ។ មូលហេតុចម្បងៗនៃបាតុភាពនេះ មានកត្តាសត្យានុម័តមួយចំនួនដូចជា ការកើននៃតម្រូវការម្ហូបអាហារពីសំណាក់ប្រជាជន ដែលចេះតែកើនឡើង ដូចជានៅប្រទេសចិន ឥណ្ឌា... ការបង្វែរផលិតផលគ្រាប់ធញ្ញជាតិទៅផលិតជីវឥន្ធនៈ ការកើនឡើងតម្លៃប្រេងដែលធ្វើឱ្យតម្លៃដើម តម្លៃដឹកជញ្ជូនកើនឡើង ការបំផ្លិចបំផ្លាញផលិតផលកសិកម្មពីគ្រោះធម្មជាតិ ការចុះតម្លៃនៃប្រាក់ដុល្លារអាមេរិក...។ល។

ក្នុងស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជាដែលមានដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាមានឧបករណ៍តិចតួចដើម្បីដឹកនាំគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដូចជាការរារាំងអំពីការប្រើប្រាស់អត្រាការប្រាក់លើប្រាក់រៀលក្នុងការកែតម្រូវបរិមាណរូបិយវត្ថុ អវត្តមានឧបករណ៍ហិរញ្ញវត្ថុ (សញ្ញាប័ណ្ណ ប័ណ្ណរតនាគារ...) សម្រាប់ប្រតិបត្តិការទីផ្សារចំហ (Open Market Operations) ។

ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិត ដោយបានកំណត់ឱ្យមានការត្រួតពិនិត្យលើកម្រិតឥណទានដោយប្រយោល កំណត់ឱ្យមានតំកល់ទុនបម្រុង ៨% លើបរិមាណសរុបនៃប្រាក់បញ្ញើ និងខិតខំរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដែលជាការចូលរួមចំណែកដោះស្រាយបញ្ហាអតិផរណាខ្ពស់នាបច្ចុប្បន្នកាល និងក្នុងអនាគតកាលដ៏ខ្លីនេះ ។

យើងបានពិភាក្សាជាមួយប្រតិបត្តិករធនាគារនិងហិរញ្ញវត្ថុ និងបានឯកភាពគ្នាដើម្បីបង្កើនទុនបម្រុងកាតព្វកិច្ច ចារិកជារូបិយប័ណ្ណ ពី ៨% ទៅ ១៦% ជាបណ្តោះអាសន្ន ព្រមទាំងកែសម្រួលវិធីគណនា និងកត្តាចូលរួមនៃទុនបម្រុងនេះ ។

បណ្តាធនាគារក្នុងប្រព័ន្ធធនាគារនៅកម្ពុជា មានស្ថានភាពសាច់ប្រាក់ងាយស្រួល (Liquidity) ខុសៗគ្នា គឺមានធនាគារខ្លះមានអតិរេកសាច់ប្រាក់ងាយស្រួលច្រើនលើសលប់ ខ្លះទៀតមានស្ថានភាពតឹងតែង ។ ការបង្កើនអត្រាទុនបម្រុងនឹងមានផលប៉ះពាល់ខុសគ្នា ចំពោះប្រភេទធនាគារខាងលើ ពិសេសប្រភេទធនាគារដែលមានកំណើនឥណទានខ្ពស់ (លើសពី ១០០% ក្នុងឆ្នាំ២០០៧) នឹងត្រូវតែមានការប្រុងប្រយ័ត្នបន្ថយល្បឿននៃកំណើនឥណទានរបស់ខ្លួនឬត្រូវខ្ចីប្រាក់ពីទីផ្សារអន្តរធនាគារ ។

ហានិភ័យសាច់ប្រាក់ងាយស្រួលជារូបិយប័ណ្ណ (ដុល្លារអាមេរិក) ផ្សារភ្ជាប់នឹងភាពផុយស្រួយនៃសេដ្ឋកិច្ច បើសិនជាមានវិបត្តិដកប្រាក់បន្ទាន់ដោយគំហុកពីធនាគារកើនឡើង ។ ការបង្កើនទុនបម្រុងកាតព្វកិច្ចជារូបិយប័ណ្ណនឹងជួយឱ្យមានរបាំងទប់ទល់ហានិភ័យនេះ ជាមួយគ្នានោះ អន្តរការិយកម្មធនាគារជាប្រាក់រៀលនឹងកើនឡើង ដោយអត្រាការប្រាក់ឥណទានជារូបិយប័ណ្ណអាចកើតឡើង ហើយអត្រាប្រាក់បញ្ញើជារូបិយប័ណ្ណនឹងថយចុះ ខណៈដែលហិរញ្ញប្បទានសេដ្ឋកិច្ចទាំងមូលពុំមានការប្រែប្រួល ដោយត្រូវផ្លាស់ប្តូរពីដុល្លារអាមេរិកមកជាប្រាក់រៀល ។ ធនាគារជាតិនៃកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា ធនាគារជាប្រតិបត្តិករទាំងអស់នឹងមានឆន្ទៈយោគយល់ដល់វិធានការបង្កើនទុនបម្រុងកាតព្វកិច្ចជារូបិយប័ណ្ណនេះជាមិនខាន ដើម្បីជាការជូនដំណឹងដល់សាធារណជន អំពីការយកចិត្តទុកដាក់របស់អាជ្ញាធរ និងពង្រឹងភាពប្រុងប្រយ័ត្ន ក្នុងការគ្រប់គ្រងហានិភ័យរបស់ប្រព័ន្ធធនាគារទាំងមូល ព្រមទាំងទប់ស្កាត់និងបន្ធូរបន្ថយសម្ពាធនៃអតិផរណាដែលបានកើនឡើងជាសាកល ក្នុងរយៈពេលចុងក្រោយនេះ ។

សូមជូនពរសព្វសាធុការ ចំពោះប្រិយមិត្តអ្នកអានទាំងអស់ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរយើង ឆ្នាំជូត (ឆ្នាំកណ្តុរ) សូមបានប្រកបតែសេចក្តីសុខ ចម្រុងចម្រើន សុភមង្គល គ្រប់ទិវារាត្រី ។

**សូមអរគុណ**

# មាតិកា

ទំព័រ


- បច្ចុប្បន្នភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា ១
- ប្រវត្តិនៃវិបត្តិ Subprime ការធក់ឱកាសកេងចំណេញលើអចលនទ្រព្យ និងការធ្លាក់ចុះនៃសេដ្ឋកិច្ច ១២
- តារាងអត្រាប្តូរប្រាក់ប្រចាំខែ ក្នុងត្រីមាសទី១ ឆ្នាំ២០០៨ ២៥
- តារាងអត្រាការប្រាក់លើការឱ្យខ្ចីចងការ (រៀលនិងរូបិយប័ណ្ណបរទេស) ប្រចាំខែមីនា ឆ្នាំ២០០៨ ២៦
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ (រៀលនិងរូបិយប័ណ្ណបរទេស) ប្រចាំខែមីនា ឆ្នាំ២០០៨ ២៧
- បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រចាំខែមីនា ឆ្នាំ២០០៨ ២៨
- ប្រព័ន្ធធនាគារនៅកម្ពុជា ប្រចាំខែមីនា ឆ្នាំ២០០៨ ៤៩

# បច្ចុប្បន្នភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅប្រទេសកម្ពុជា

## ១. កំណើនសេដ្ឋកិច្ច (Economic Growth)

សេដ្ឋកិច្ចកម្ពុជានៅតែមានដំណើរការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសេដ្ឋកិច្ចនេះអាចរក្សាបាននូវកំណើនសេដ្ឋកិច្ចមួយ ដែលមានលេខពីរខ្ទង់ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ។ ផ្អែកតាមសូចនាករថ្មីៗ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រមាណ ១០.១% ក្នុងឆ្នាំ២០០៧ ដែលមូលហេតុសំខាន់បានមកពីភាពរឹងមាំខាងវិស័យសេវាកម្ម សកម្មភាពខ្លាំងក្លាខាងវិស័យសំណង់ និងការបន្តកើនឡើងនៃកំណើនខាងវិស័យកសិកម្ម ព្រមទាំងវិស័យកាត់ដេរ ទោះបីកំណើននោះមានល្បឿនធ្លាក់ចុះបន្តិចក៏ដោយ ។ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨ ត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រមាណ ៧.២% ។

The Cambodian economy has continued to perform quite impressively. The economy has achieved a double digit growth rate over the past three years. The current trend also looks very favorable. Based on recent indicators, real GDP growth in 2007 was projected to be 10.1%, driven mainly by a robust service sector, ample construction activities and continuous positive growth in the agriculture sector, as well as in garment manufacturing, though at a declining pace. The real GDP growth in 2008 is projected to be 7.2%.




## ២. ថ្លៃលក់រាយ និងអតិផរណា (Retail Prices and Inflation)

នៅឆ្នាំ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បានបន្តកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីខែមករាមក អត្រាអតិផរណាគិតតាមបម្រែបម្រួលឆ្នាំលើឆ្នាំបានកើនឡើង ១០.៨% ក្នុងខែធ្នូ ឆ្នាំ២០០៧ ធៀបនឹង ២.៨% ក្នុងខែធ្នូ ឆ្នាំ២០០៦ និង ៦.៧% ក្នុងខែធ្នូ ឆ្នាំ២០០៥ ។ ការកើនឡើងនៃថ្លៃម្ហូបអាហារជាកត្តារួមចំណែកធំបំផុត ក្នុងកំណើនអតិផរណាសរុបក្នុងឆ្នាំ២០០៧ បន្ទាប់មកសន្ទស្សន៍រងដឹកជញ្ជូននិងទូរគមនាគមន៍ក៏បានរួមចំណែកជាមួយសន្ទស្សន៍រងផ្ទះសម្បែងនិងការប្រើប្រាស់ ធ្វើឱ្យអតិផរណាកើន ។

During 2007, the consumer price index rose gradually since January to reach a year-on-year change of 10.8 percent in December, compared to the annual inflation rate of 2.8 percent and 6.7 percent in 2006 and 2005, respectively. The increase in the prices of food accounted for the largest contribution to the observed increase in inflation, while the sub-index of Transportation & Telecommunication Coupled with Housing & Utilities pushed up the overall inflation rate.




សម្ពាធលើអតិផរណា កើនឡើងជាចម្បងដោយសារផលប៉ះពាល់នៃការផ្គត់ផ្គង់មកលើថ្លៃ ដែលឆ្លុះបញ្ចាំងពីផលិតកម្មនេសាទមានកម្រិតទាប និងឥទ្ធិពលនៃជម្ងឺផ្តាសាយបក្សី ។ អតិផរណាខ្ពស់នេះ ក៏ជាលទ្ធផលនៃឥទ្ធិពលរួមផ្សំនៃការឡើងថ្លៃប្រេងដ៏ខ្ពស់ និងការឡើងថ្លៃទំនិញដទៃទៀតលើពិភពលោក អតិផរណាខ្ពស់នៃទំនិញនាំចូល និងការធ្លាក់ថ្លៃប្រាក់ដុល្លារអាមេរិក ហើយសម្ពាធនេះកាន់តែខ្លាំងឡើងដោយការកើនឡើងតម្រូវការក្នុងស្រុក ដែលពាក់ព័ន្ធនឹងកំណើនលំហូរចូលដើមទុន និងការឡើងថ្លៃអចលនទ្រព្យ ។ ក្នុងអំឡុងឆ្នាំ២០០៧នេះ តម្លៃប្រេងគ្រប់ប្រភេទដែលដាក់លក់ក្នុងទីផ្សារក្នុងស្រុកបានកើនឡើងជាបន្តបន្ទាប់ ដែលក្នុងនោះតម្លៃប្រេងសាំងបានកើនឡើង ១០,១% ប្រេងម៉ាស៊ូតកើន ១៨,២% និងប្រេងម៉ាស៊ីនកើន ២៦,៩% ។ ប្រសិនបើមិនរាប់បញ្ចូលតម្លៃម្ហូបអាហារ អត្រាអតិផរណាឆ្នាំលើឆ្នាំគឺមានកម្រិតត្រឹមតែ ៣,៨% ប៉ុណ្ណោះ ។

The pressures on the inflation rooted largely in the impact of supply-side shocks on prices, which reflected lower fishery production and the impact of avian flu. They were also a result of a combination effect of high world oil and other commodity prices, imported inflation, and the weak USD, which was somewhat intensified by an increase in local demand associated with rising capital inflows and property prices. During the year, pump prices for all kinds of fuels sold in the domestic market increased, with the prices of gasoline, diesel fuel, and motor oil up by 10.1 percent, 18.2 percent, and 26.9 percent respectively. When excluding food prices, y-o-y inflation rate stood at 3.8%.



បម្រែបម្រួលប្រចាំឆ្នាំនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មធ្យមរំកិល៣ខែបានកើនឡើងរហូតដល់ ៩,៧% នៅខែធ្នូ ឆ្នាំ២០០៧ បើធៀបនឹង ៣,៤% កាលពីឆ្នាំមុន ដែលបញ្ជាក់ពីការកើនឡើងយ៉ាងខ្លាំងនៃថ្លៃទំនិញក្នុងអំឡុងពេលចុងឆ្នាំ ។ ផ្ទុយទៅវិញ អតិផរណាមធ្យមប្រចាំឆ្នាំ បានកើនឡើងត្រឹមតែ ៥,៨% នៅខែធ្នូ ឆ្នាំ២០០៧ ធៀបនឹង ៤,0% នាឆ្នាំកន្លងទៅ ។

The annual change in CPI based on the three-month moving average indexes rose to 9.7% in December 2007, compared to 3.4 percent in December 2006, indicating a strong price increase during the year-end period. The annual average inflation, on the other hand, rose to only 5.8% in December 2007, against 4% in December 2006.

### ៣. ចលនានៃអត្រាប្តូរប្រាក់ (Exchange Rate Movements)

ជាទូទៅ ប្រាក់រៀលដែលវាស់ដោយអត្រាទិញទីផ្សារគឺមានភាពរឹងមាំ ដោយប្រែប្រួលក្នុងចន្លោះ ពី ៣.៩៩៦រៀល ទៅ ៤.0៩៦រៀល ក្នុង១ដុល្លារអាមេរិក ធៀបនឹងការប្រែប្រួលចន្លោះពី ៤.0៣0 ទៅ ៤.២00រៀល ក្នុង១ដុល្លារអាមេរិកនៅឆ្នាំ២00៦ ។ បើពិនិត្យមើលនិន្នាការអត្រាប្តូរប្រាក់នាឆ្នាំមុនៗ ប្រាក់រៀលតែងបានឡើងថ្លៃក្នុងអំឡុងរយៈពេលចុងឆ្នាំ ។ ក្នុងឆមាសទី២ ឆ្នាំ២00៧ ប្រាក់រៀលត្រូវបានទិញ-លក់ក្នុងអត្រាមធ្យមស្មើនឹង ៤.0៥៣រៀល ក្នុង១ដុល្លារអាមេរិក ធៀបនឹង ៤.១៣៤រៀល ក្នុងរយៈពេលដូចគ្នានៃឆ្នាំកន្លងទៅ ។ ផ្អែកលើបម្រែបម្រួលឆ្នាំលើឆ្នាំ ប្រាក់រៀលបានឡើងថ្លៃ ១,៤% ធៀបនឹងប្រាក់ដុល្លារអាមេរិក ដោយអត្រាប្តូរប្រាក់ទីផ្សារបានធ្លាក់ចុះពី ៤.0៥៨រៀល ក្នុង១ដុល្លារដុល្លារអាមេរិក នៅចុងឆ្នាំ២00៦ មកត្រឹម ៤.000រៀលក្នុង១ដុល្លារអាមេរិក នៅចុងឆ្នាំ២00៧ ។ ការឡើងថ្លៃនៃប្រាក់រៀលបានក្លាយជាបាតុភូតរដូវកាល ព្រោះអ្នកនាំចេញ និងឈ្មួញក្នុងស្រុកតែងតែត្រូវការរូបិយវត្ថុជាតិក្នុងចំនួនច្រើន ដើម្បីទិញផលិតផលកសិកម្មពីកសិករនៅរដូវច្រូតកាត់ ។ ក្រៅពីនេះ តម្រូវការប្រាក់រៀលបានកើនឡើង ដោយសារអង្គភាពអាជីវកម្មមានតម្រូវការបង់ពន្ធ ដែលជាការឆ្លុះបញ្ចាំងពីកំណើនសេដ្ឋកិច្ចដ៏រឹងមាំ។ ការកើនឡើងនៃលំហូរដើមទុន តាមរយៈការឆ្លុះបញ្ចាំងការកើនឡើងនៃអតិរេកស្ថិតិជញ្ជីងទូទាត់ ក៏រួមចំណែកក្នុងការពង្រឹងរូបិយវត្ថុជាតិក្នុងឆ្នាំ២00៧នេះផងដែរ ។

On the whole, the riel as measured by the market purchase rate was strong, moving only within the range of 3,996 riel and 4,096 riel per US dollar against a fluctuation between 4,030 and 4,200 riel per US dollar, in 2006. Following the trends of the preceding years, the riel exchange rate showed also some appreciation in the period toward the end of the year. In the second half of 2007, the riel was traded at an average rate of 4,053 riel per US dollar, as compared to 4,134 riel in the same period of the previous year. Based on a year on year basis, the riel gained value by 1.4 percent against the US dollar, as the market exchange rate went down from 4,058 riel per US dollar at



the end of 2006 to 4,000 riel per US dollar at the end of 2007. The appreciation of the riel could be explained as a seasonal phenomenon because exporters and local traders usually need the national currency in a large amount in order to purchase from the farmers agricultural products in the harvest season. Besides reflecting steady economic growth, there was increased demand for riel by corporations to pay their tax obligations. Rising capital inflow as reflected in a growing balance of payments surplus may also have contributed to the strength of the local currency during 2007.

## ៤. ការវិវឌ្ឍនៃរូបិយវត្ថុ (Monetary Development)

ល្បឿននៃកំណើនរូបិយវត្ថុបានកើនឡើងយ៉ាងរហ័សនៅឆ្នាំ២០០៧នេះ ដោយសារតែការកើនឡើងទាំងទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារ ទាំងទ្រព្យសកម្មក្នុងស្រុកសុទ្ធ ។ កម្រិតនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធដែលធ្លាប់តែមានសញ្ញាអវិជ្ជមានអស់រយៈពេលជាច្រើនឆ្នាំមកហើយ បានបង្ហាញពីសញ្ញាវិជ្ជមានវិញ ក្នុងឆ្នាំ២០០៧នេះ ។ ស្ថានភាពវិជ្ជមានរបស់ទ្រព្យសកម្មក្នុងស្រុកសុទ្ធ បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការកើនឡើងគួរឱ្យកត់សម្គាល់នៃឥណទានក្នុងស្រុក ជាពិសេសបំណុលទៅផ្នែកឯកជនមិនមែនធនាគារ ។ កំណើននេះគឺមានល្បឿនកើនឡើងដូចគ្នាទៅនឹងល្បឿននៃកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ។ ទន្ទឹមនឹងនេះដែរ រូបិយវត្ថុជាតិក្រៅធនាគារក៏មានកំណើនយ៉ាងរឹងមាំផងដែរ បើធៀបនឹងឆ្នាំមុន ។

The pace of monetary growth quickened during the reporting year as the net foreign assets of the banking system and net domestic assets both increased. The level of net domestic assets, which posted a negative sign for many years, reversed its trend in 2007. The positive position of net domestic assets is mainly attributable to a remarkable surge in domestic credit, particularly loans to the non-bank private sector. Such growth was in turn accompanied by an increase at about the same pace of foreign currency deposits. Meanwhile, local currency outside banks recorded a steady growth as compared to the previous year.

### ៤.១- សមាសធាតុរូបិយវត្ថុ (Monetary Aggregates)

បន្ទាប់ពីមានកំណើន ៣៨.២% នៅឆ្នាំមុន រូបិយវត្ថុទូទៅ (M2) ក្នុងឆ្នាំ២០០៧ បានកើនឡើងកាន់តែលឿនជាងមុន គឺកើនចំនួន ៤.៣៦៨.៤ ពាន់លានរៀល (៦២.៩%) ដោយកើនឡើងពី ៦.៩៤២.៣ ពាន់លានរៀលនៅខែធ្នូ ឆ្នាំ២០០៦ មកដល់ ១១.៣១០.៧ ពាន់លានរៀលនៅខែធ្នូ ឆ្នាំ២០០៧ ។ ការកើនឡើងនេះគឺឆ្លុះបញ្ចាំងពីកំណើនក្នុងរូបិយវត្ថុ (M1) និងរូបិយវត្ថុផ្សេងៗ ។

After having gained 38.2 percent in the preceding year, broad money (M2) expanded at a faster pace during the reviewed year, rising by 4,368.4 billion riel (62.9 percent) from 6,942.3 billion riel in December 2006 to 11,310.7 billion riel in December 2007. This increase reflected an expansion in both narrow money (M1) and quasi money.

រូបិយវត្ថុ (M1) ដែលមានចំនួនប្រមាណ ១៨% នៃរូបិយវត្ថុទូទៅ (M2) បានកើនឡើងបន្ថែម ២៣.៨% ក្នុងកំឡុងឆ្នាំ២០០៧នេះ ។ រូបិយវត្ថុក្រៅប្រព័ន្ធធនាគារបានកើនឡើងចំនួន ៣៩០.២ ពាន់លានរៀល (២៤.៤%) បើប្រៀបធៀបនឹងកំណើន ៣១៧.៤ ពាន់លានរៀល (២៤.៨%) កាលពីឆ្នាំ២០០៦ ។ គេកត់សម្គាល់ឃើញថា

ការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារក្នុងអំឡុងឆ្នាំ២០០៧នេះ គឺកើតឡើងចំពេលដែលអត្រាប្តូរប្រាក់របស់រូបិយវត្ថុជាតិនៅតែបន្តមានស្ថិរភាព ដែលឆ្លុះបញ្ចាំងពីកំណើនតម្រូវការរូបិយវត្ថុជាតិ សម្រាប់ប្រតិបត្តិការឆ្នាំ២០០៧ ។ ទន្ទឹមនោះដែរ ប្រាក់បញ្ញើជារូបិយវត្ថុជាតិដែលអាចដកបានតាមតម្រូវការ បានកើនឡើងតិចតួច ប្រមាណ ៧,១% ប៉ុណ្ណោះធៀបនឹងកំណើន ៤៣% ក្នុងឆ្នាំ២០០៦ ដែលអាចនិយាយបានថាមកពីការយល់ដឹងរបស់សាធារណជនពីថ្លៃឱកាសនៃការរក្សាប្រភេទគណនីសន្សំបែបនេះ ។

Narrow money (M1), which accounted for about 18 percent of M2, grew by 23.8 percent during 2007. Currency outside the banking system rose by 390.2 billion riel (24.4 percent) compared to the growth of 317.4 billion riel (24.8 percent) recorded a year ago. It should be noted that the increase in the currency outside banks during the year under consideration occurred at a time when the exchange rate of the national currency remained broadly stable, reflecting the growing demand for local currency for transactions during 2007. Meanwhile, deposits denominated in local currency and withdrawable on demand accelerated only slightly, up by 7.1 percent as against a 43 percent increase in the preceding year, which may be explained by the public’s awareness of the opportunity cost of maintaining this type of savings.

រូបិយវត្ថុផ្សេងៗ ដែលរួមមានប្រាក់បញ្ញើមានកាលកំណត់និងប្រាក់បញ្ញើសន្សំជារូបិយវត្ថុជាតិ និងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស បានកើនឡើងយ៉ាងខ្លាំងស្មើនឹង ១,៧ដង នៃកម្រិតនៅចុងឆ្នាំ២០០៦ ។ ប្រាក់បញ្ញើមានកាលកំណត់និងសន្សំជារូបិយវត្ថុជាតិ បានរួមចំណែកដល់បម្រែបម្រួលនេះ ដែលមានកំណើនចំនួន ៣២,៤ពាន់លានរៀល (៣៦,៦%) ។ ទោះយ៉ាងណាក៏ដោយ ចំណែកភាគច្រើននៃការកើនឡើងនៃរូបិយវត្ថុផ្សេងៗនេះ គឺបានមកពីកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសរបស់និវាសជន ។ ប្រាក់បញ្ញើនេះ បានកើនឡើងចំនួន ៣.៩៤១,៧ ពាន់លានរៀល ឬ ៧៥,៩% ដែលជាអត្រាកំណើនដ៏ខ្ពស់បំផុតក្នុងរយៈពេលជាងមួយទសវត្សរ៍នេះ ។ កំណើនដ៏គួរឱ្យកត់សម្គាល់នេះ គឺបានមកពីកំណើនប្រាក់បញ្ញើសន្សំជារូបិយប័ណ្ណបរទេសចំនួន ២.២៩៣,៧ពាន់លានរៀល (១០៣,១%) ប្រាក់បញ្ញើមានកាលកំណត់ ៩៤៩,៨ពាន់លានរៀល (៩២,៤%) និងប្រាក់បញ្ញើចរន្ត ៩១៩,២ពាន់លានរៀល (៦៦%) ។ ទិន្នន័យប្រចាំខែសម្រាប់ឆ្នាំ២០០៧ បានបង្ហាញថាប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានកំណើនជាវិជ្ជមានស្ទើរតែជារៀងរាល់ខែ លើកលែងតែខែតុលា ដែលមានការថយចុះបន្តិច ។




Quasi-money, which comprises of local currency fixed & saving deposits and foreign currency deposits, recorded a sharp increase to reach more than 1.7 times the level recorded at the end of 2006. Local currency fixed & saving deposits contributed to this change with a growth of 32.4 billion riel (36.6 percent). However, greatest factor in the rise in quasi-money was growth in resident’s foreign currency deposits. This item was up by 3,941.7 billion riel (75.9 percent), its highest growth rate in more than a decade. The considerable pick-up

in the growth of this latter item reflected the growth of 2.293,7 billion riel (103.1 percent), 949.8 billion riel (52.4 percent), 919.2 billion riel (66 percent) in savings, fixed, and demand deposits denominated in foreign currency, respectively. The monthly data for 2007 showed that foreign currency deposits posted a positive growth in almost every month, except for October where a slight decrease was observed.

### ៤.២- កត្តាជះឥទ្ធិពលលើការផ្គត់ផ្គង់រូបិយវត្ថុ (Factors affecting Money Supply)

ការកើនឡើងយ៉ាងខ្លាំងនៃរូបិយវត្ថុក្នុងឆ្នាំ២០០៧ បានឆ្លុះបញ្ចាំងពីកំណើនគួរឱ្យកត់សម្គាល់នៃទ្រព្យសកម្មបរទេសសុទ្ធក្នុងប្រព័ន្ធធនាគារ ដែលកើនឡើងចំនួន ៣.៥១០,៤ពាន់លានរៀល (៤៨,៦%) រួមនឹងការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធចំនួន ៨៥៨ពាន់លានរៀល (៣០៤,២%) ។ ជាលទ្ធផល ទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារចូលរួមចំណែក ៥០,៦% នៃកំណើនសាច់ប្រាក់ងាយស្រួលសរុប ៦២,៩% បានន័យថា ៨០,៣% នៃកំណើនសរុបក្នុងរូបិយវត្ថុទូទៅ (M2) ។ ការចូលរួមចំណែកនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធទៅក្នុងកំណើន ៦២,៩% នៃរូបិយវត្ថុទូទៅ (M2) គឺមានចំនួន ១២,៤% ហើយវាមានចំណែក ១៩,៦% នៃកំណើនសាច់ប្រាក់ងាយស្រួលសរុប ។

The strong monetary expansion during 2007 reflected a substantial increase in net foreign assets of the banking system coupled with a large rise in net domestic assets, which rose by 3,510.4 billion riel (48.6 percent) and 858 billion riel (304.2 percent), respectively. As a consequence, of the total liquidity growth of 62.9 percent, net foreign assets of the banking system contributed 50.6 percent, i.e. 80.3 percent of the total growth in M2. The contribution of net domestic assets to the 62.9 increase in M2 was 12.4 percent, taking up 19.6 percent of the total observed liquidity expansion.




កំណើនដ៏ខ្ពស់នៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺបណ្ដាលមកពីការកើនឡើងទាំងស្រុងនៃឥណទានក្នុងស្រុកសុទ្ធ ដែលត្រូវបានកាត់បន្ថយមួយចំណែកដោយការធ្លាក់ចុះនៃធាតុដទៃទៀតសុទ្ធ ដោយសារការកើនឡើងនៃដើមទុនធនាគារដល់ ១.០៧០,៦ពាន់លានរៀល (៣៣%) ។

The high growth in net domestic asset in 2007 was driven entirely by an increase in net domestic credit, which was partly offset by a decline in other items (net) as a result of a surge in bank capital amounting to 1,070.6 billion riel (33 percent).

ឥណទានក្នុងស្រុកសុទ្ធបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០០៧ ដោយតម្រូវការឥណទានបានកើនឡើងជាមួយកំណើនសេដ្ឋកិច្ចមានភាពរឹងមាំ និងទស្សនៈវិស័យសេដ្ឋកិច្ចដ៏ល្អប្រសើរនាពេលអនាគត ។ អត្រាកំណើនឥណទានក្នុងស្រុកប្រចាំឆ្នាំបានកើនឡើងដល់ ៧០,៧% ធៀបនឹងកំណើន ៣៥,៧% កាលពីឆ្នាំមុន ។ ការកើនឡើងនេះគឺដោយសារតែកំណើនដ៏ខ្លាំងនៃឥណទេយ្យចំពោះវិស័យឯកជន ចំនួន ៧៦% តាមបម្រែបម្រួលឆ្នាំលើឆ្នាំ ដែលជា

អត្រាខ្ពស់ជាងគេបំផុតក្នុងរយៈពេលជាច្រើនឆ្នាំនេះ ។ ផ្ទុយទៅវិញ ការធ្លាក់ចុះ ៩០,៥% នៃឥណទេយ្យសុទ្ធរបស់រដ្ឋាភិបាលបានកាត់បន្ថយឥទ្ធិពលរបស់កំណើនឥណទានក្នុងស្រុក ។

Net domestic credit expanded considerably in 2007, with credit demand rising as economic growth was sustained and future economic prospects continued to be promising. The annual rate of net domestic credit growth accelerated to 70.7 percent, from 35.7 percent in 2006. This rise was solely attributable to strong growth in claims on private sector, which went up by 76 percent on a year-on-year basis and thus represented the highest rate observed in many years. In contrast, a 90.5 percent drop in net claims on central government had a dampening effect on domestic credit growth.

ពាក់ព័ន្ធនឹងការចូលរួមនៃឥណទានក្នុងកំណើនខាងលើនេះ កំណើនឥណទានក្នុងឆ្នាំ២០០៧ បណ្ដាលមកពីការឱ្យខ្ចីបន្ថែមទៅលើវិស័យមួយចំនួន ពោលគឺ ផ្នែកសេវាកម្មកើនឡើង ៦៥៧,២ពាន់លានរៀល (៥៧,៤%) ផ្នែកលក់ដុំនិងលក់រាយ ៥៨៧,៨ពាន់លានរៀល (៧៥%) ការប្រើប្រាស់ផ្ទាល់ខ្លួន ៥៧៣,៩ពាន់លានរៀល (៤០៧,៧%) វិស័យសំណង់ ៣៧០,៨ពាន់លានរៀល (១៣៧,៤%) ផលិតកម្ម ២១៤,៩ពាន់លានរៀល (៥២,៤%) ការប្រើប្រាស់សាធារណៈនិងអចលនវត្ថុ ១៩៦,៦ពាន់លានរៀល (៦៥,៨%) និងវិស័យកសិកម្ម ១៥៦,៦ពាន់លានរៀល (១០៥%) ធៀបនឹងឆ្នាំ២០០៦ ។

With regard to the distribution of credit, this year's credit growth was fuelled mainly by further lending to a number of promising sectors, which showed the following growth on the outstanding balance in 2006 services: 657.2 billion riel (57.4 percent); wholesale and retail: 587.8 billion riel (75 percent); personal consumption: 573.9 billion riel (407.7 percent); construction: 370.8 billion riel (137.4 percent); manufacturing: 214.9 billion riel (52.4 percent); real estate & public utilities: 196.6 billion riel (65.8 percent); and agriculture: 156.6 billion riel (105 percent).




## ៥. ស្ថិតិជញ្ជីងទូទាត់ (Balance of Payments)

តាមទិន្នន័យបាន់ស្មានដំបូងក្នុងឆ្នាំ២០០៧នេះ ស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា បង្ហាញនូវសមតុល្យរួម ចំនួន ២៩០លានដុល្លារអាមេរិក គឺកើនឡើងចំនួន ៨៨ លានដុល្លារអាមេរិកធៀបនឹងឆ្នាំ២០០៦ ។ មូលហេតុសំខាន់នៃកំណើនអតិរេកនេះ គឺបណ្ដាលមកពីការកើនឡើងនៃសមតុល្យគណនីដើមទុននិងហិរញ្ញវត្ថុ ចំនួន ៩៣,៩លានដុល្លារអាមេរិក (១២%) រួមផ្សំនឹងការថយចុះនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ) ចំនួន ៤៦,២លានដុល្លារអាមេរិក (៨,៨%) ។ ជាលទ្ធផល អនុបាតនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ) លើ GDP បានថយចុះដល់ ៦,៦% ក្នុងឆ្នាំ២០០៧ ធៀបនឹង ៧,២%នៅឆ្នាំមុន ។

The preliminary estimates of the balance of payments of Cambodia for the year 2007 showed an overall balance of US$ 290 million, an increase of US$ 88 million compared to 2006. The increase surplus mainly resulted from an increase in the capital and financial account balance of US$ 93.9 million (12 percent), coupled with a decrease in the current account deficit (excluding official transfers) of US$ 46.2 million (8.8 percent). Consequently, the ratio of the current account deficit (excluding official transfers) to GDP went down to 6.6 percent in 2007 against 7.2 percent in the preceding year.




## ៥.១- គណនីចរន្ត-មិនរាប់បញ្ចូលបង្វែរផ្លូវការ (Current Account-Excluding Official Transfers)

ឱនភាពគណនីចរន្តត្រូវបានគេប៉ាន់ស្មានថាមានចំនួន ៥៧១,២លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧ ពោលគឺកើនឡើងចំនួន ៨,៨% ធៀបនឹងឱនភាពនាឆ្នាំមុន ។ ការកើនឡើងនៃឱនភាពគណនីជញ្ជីងពាណិជ្ជកម្ម ចំនួន ២០,៣% គឺជាកត្តាចម្បងដែលធ្វើឱ្យឱនភាពគណនីចរន្តរឹតតែកើនខ្លាំងឡើង ។ ខណៈពេលនោះដែរ ការកើនឡើងនៃអតិរេកសេវាសុទ្ធចំនួន ២៧,១% និងការថយចុះនៃឱនភាពប្រាក់ចំណូលសុទ្ធចំនួន ៤,៧% បានកាត់បន្ថយឥទ្ធិពលនៃការកើនឡើងឱនភាពគណនីចរន្ត ។

The current account deficit was estimated at US$ 571.2 million in 2007, an increase of 8.8 percent on the 2006 deficit. The increase in trade deficit of 20.3 percent was the main contributor explaining the escalation in the current account deficit. At the same time, the increase in net service surplus of 27.1 percent and the decrease in net income deficit of 4.7 percent exercised a dampening effect on the rise in the current account deficit.

នៅឆ្នាំ២០០៧ ការនាំចេញក្នុងស្រុកមានចំនួន ៣.៨៥៦,៨លានដុល្លារអាមេរិក គឺកើនឡើង ៣១៩,៦ លានដុល្លារអាមេរិក (៩%) ធៀបនឹងឆ្នាំ២០០៦ ។ ការកើនឡើងនេះគឺបណ្តាលមកពីកំណើននៃតម្លៃការនាំចេញផ្នែកកាត់ដេរ ដែលមានចំនួន ២៨៧,៨លានដុល្លារអាមេរិក (១០,៦%) គឺច្រើនជាងកំណើននៅ ឆ្នាំ២០០៥ ប៉ុន្តែតិចជាងកំណើនឆ្នាំ២០០៦ ចំនួន១,៦ដង ។ ការអនុវត្តរបស់ប្រទេសកម្ពុជា អនុលោមតាមស្តង់ដារពិភពលោក លើលក្ខខណ្ឌការងារនិងប្រាក់ឈ្នួលទាបល្មមក្នុងវិស័យកាត់ដេរនេះ នៅតែបន្តគាំទ្រដល់ឧស្សាហកម្ម ។ ទោះយ៉ាងណាក៏ដោយ ដើម្បីដោះស្រាយឱ្យបានជោគជ័យនូវភាពលំបាកដែលកើតពីការប្រកួតប្រជែងកម្រិតពិភពលោក និងកម្រិតតំបន់ដែលរួមមានប្រទេសចិននិងវៀតណាម ប្រទេសកម្ពុជាត្រូវការកែលម្អបន្ថែមទៀតទៅលើប្រសិទ្ធភាពរបស់ឧស្សាហកម្ម ។ គេកត់សម្គាល់ឃើញថា ការនាំចេញផ្នែកកាត់ដេរនៅតែជាធាតុសំខាន់នាំមុខគេ ដែលរួមចំណែក ៧៨,២% នៃការនាំចេញរបស់ប្រទេសកម្ពុជាទាំងមូលក្នុងឆ្នាំ២០០៧ ។ ជាមួយគ្នានេះដែរ ការនាំចេញផ្សេងៗទៀតបានកើនឡើង ចំនួន ៣១,៨ លានដុល្លារអាមេរិក (៤%) ធៀបនឹងឆ្នាំ២០០៦ ដែលឆ្លុះបញ្ចាំងពីការកើនឡើងជាចម្បងនៃការនាំចេញអង្ករ គ្រឿងសង្ហារឹម និងផលិតផលកសិកម្មដទៃទៀត ។




In 2007, domestic exports amounted to US$ 3,856.8 million, an increase of US$ 319.6 million (9 percent) compared to 2006. This increase was mainly driven by the upsurge in the value of garment exports of US$ 287.8 million (10.6 percent), which was higher than 2005 growth, but 1.6 times smaller than growth in 2006. Cambodia's compliance with the global standards on labor conditions and the relative low wages in the garment sector continued to be supportive for the industry. However, in order to successfully confront the challenges arising from global and regional competition, including those presented by China and Vietnam, Cambodia will need to further improve the industry's efficiency. It should be noted that garment exports remained the leading component, accounting for 78.2 percent of Cambodia's domestic exports in 2007. In the same period, other domestic exports rose by US$ 31.8 million (4 percent) compared to 2006, reflecting an increased export of rice, furniture and assorted agriculture products.

ក្នុងឆ្នាំ២០០៧នេះដែរ ការនាំចូលត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៥.១៤៣លានដុល្លារអាមេរិក គឺកើនឡើង ៥២៩,៤លានដុល្លារអាមេរិក (១១,៥%) ធៀបនឹងឆ្នាំ២០០៦ ។ កត្តាដែលរួមចំណែកយ៉ាងសំខាន់ក្នុងកំណើននេះ គឺការកើនឡើងនូវតម្លៃប្រេងនាំចូលចំនួន ១៣២,៩លានដុល្លារអាមេរិក (១១,៨%) ។ តម្លៃនៃប្រេងនាំចូលនេះមានចំនួន ២៤,៤% នៃការនាំចូលសរុប ។ លើសពីនេះ ការនាំចូលវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរបានកើនឡើងចំនួន ៨,៥% ខណៈដែលការនាំចូលដទៃទៀតកើនឡើងចំនួន ១៣% ។

In 2007, retained imports were estimated at US$ 5,143 million, an increase of US$ 529.4 million (11.5 percent) compared to 2006. The main contributor to this increase was the rise in the value of petroleum import of US$ 132.9 million (11.8 percent). The value of fuel imports accounted for 24.4 percent of retained imports. In addition, import of raw materials for the garment industry grew by 8.5 percent, while other retained import was up by 13 percent.

ក្នុងកំឡុងពេលនេះដែរ អតិរេកគណនីសេវាសុទ្ធបានកើនដល់ ៦៤៣,៩លានដុល្លារអាមេរិក គឺកើនឡើងចំនួន ១៣៧,៥លានដុល្លារអាមេរិក (២៧,១%) លើសពីឆ្នាំ២០០៦ ។ ការកើនឡើងនេះគឺជាលទ្ធផលនៃចំណូលសេវាដែលមានចំនួនលើសការចំណាយសេវាទៅលើអនិវាសជន ។ ចំណូលពីទេសចរណ៍ និងពីសេវាដឹកជញ្ជូន គឺជាកត្តាសំខាន់ដែលនាំឱ្យមានកំណើនគណនីសេវាសុទ្ធនេះ ។ នៅឆ្នាំ២០០៧នេះ ចំនួនភ្ញៀវទេសចរបរទេសដែលមកដល់ប្រទេសកម្ពុជាបានកើនឡើងដល់ ២.០៣២.៧៥៤ នាក់ ធៀបនឹងចំនួន ១.៧០០.០៤១ នាក់ នៅឆ្នាំ២០០៦ ដែលឆ្លុះបញ្ចាំងពីកិត្តិសព្ទរបស់ប្រទេសកម្ពុជាក្នុងនាមជាទីកន្លែងគោលដៅទេសចរណ៍ ។ ការប៉ាន់ស្មានឱនភាពគណនីប្រាក់ចំណូល មានចំនួន ២៧៦,៧ លានដុល្លារអាមេរិក គឺថយចុះចំនួន ១៣,៧លានដុល្លារអាមេរិក (៤,៧%) ពីឱនភាពនៅឆ្នាំ២០០៦ ។ ការថយចុះនេះ គឺសំខាន់មកពីការថយចុះនៃការផ្ទេរចំណូលទៅម្ចាស់ភាគហ៊ុនរបស់អនិវាសជន ។ ទន្ទឹមនឹងនោះដែរ ការផ្ទេរឯកជនសុទ្ធត្រូវបានប៉ាន់ស្មានឃើញថា មានអតិរេកចំនួន ៣៣២លានដុល្លារអាមេរិក គឺកើនលើសឆ្នាំ២០០៦ ចំនួន ១៦,៩លានដុល្លារអាមេរិក (៥,៤%) ដោយសារតែការផ្ទេរលុយពីជនជាតិកម្ពុជាដែលរស់នៅបរទេស ។

During the same period, the net services account surplus reached US$ 643.9 million, a rise of US$ 137.5million (27.1 percent) on the surplus in 2006. This increase was the result of service receipts exceeding service payments to non-residents. Tourism receipts and proceeds from transportation services were the main contributors to this increase. This reporting year saw the number of foreign visitor arrivals in Cambodia increasing to 2,032,754 compared to 1,700,041 in 2006, reflecting the improved popularity of Cambodia as a tourist destination. The estimated deficit on the income account was US$ 276.7 million, a decrease of US$ 13.7 million (4.7 percent) from the deficit in 2006. This fall was mainly attributable to a decrease in income remittances to non-residents' shareholders. Meanwhile, net private transfers were estimated to be a surplus of US$ 332 million, up by US$ 16.9 million (5.4 percent) on 2006, mainly mirroring remittances from Cambodians abroad.

### ៥.២- គណនីដើមទុន និងហិរញ្ញវត្ថុ

សមតុល្យនៃគណនីចរន្តនិងគណនីដើមទុន មានឱនភាពចំនួន ១៥៥,៣លានដុល្លារអាមេរិក នៅឆ្នាំ២00៧ ធៀបនឹងឱនភាពចំនួន ៧៥,៨ លានដុល្លារអាមេរិកនៅឆ្នាំ២00៦ ។ លំហូរចូលនៃបង្វែរផ្លូវការសុទ្ធ គឺមានប្រមាណជាង ៤១៦លានដុល្លារអាមេរិក ដោយថយចុះចំនួន ៣៣,២លានដុល្លារអាមេរិក (៧,៤%) ធៀបនឹងឆ្នាំមុន ។ លំហូរចូលបែបនេះ បានឆ្លុះបញ្ចាំងពីជំនួយផ្នែកហិរញ្ញវត្ថុដែលរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ទទួលបានពីដៃគូអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគី ដែលរួមបញ្ចូលមានការគាំទ្រថវិកា ចំនួន ២១,៣ លានដុល្លារអាមេរិក ជំនួយម្ហូបអាហារ ចំនួន ២៩,៤ លានដុល្លារអាមេរិក ជំនួយគម្រោង ចំនួន ១៨៦,៦លានដុល្លារអាមេរិក និងហិរញ្ញប្បទានជំនួយបច្ចេកទេស ចំនួន ១៧៩លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះដែរ កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលឥណទានពី IMF) គឺមានប្រមាណជា ១៧៣លានដុល្លារអាមេរិក ដោយកើនឡើងចំនួន ៤១% ធៀបនឹងឆ្នាំមុន ។ នៅឆ្នាំ២00៧ លំហូរចូលដើមទុនក្នុងទម្រង់ជាការវិនិយោគបរទេសផ្ទាល់សុទ្ធគឺមានលក្ខណៈគួរឱ្យកត់សម្គាល់ ដោយកើនដល់ ៧១១,២លានដុល្លារអាមេរិក ។ ក្នុងតួលេខសរុបនេះ ការវិនិយោគក្នុងវិស័យក្រៅពីធនាគារបានកើនដល់ ៦១៨,១លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងពីការវិនិយោគដ៏ច្រើនក្នុងវិស័យទូរគមនាគមន៍ បន្ទាប់មកគឺវិស័យកាត់ដេរនិងកសិកម្ម ។ ការវិនិយោគបន្ថែមមួយចំនួនគឺមានក្នុងវិស័យសណ្ឋាគារនិងរមណីយដ្ឋាន ភេសជ្ជៈ ការវេចខ្ចប់ មន្ទីរពេទ្យ និងផលិតកម្មស្បែកជើង ។




The balance on the current and capital accounts was a deficit of US$ 155.3 million in 2007 compared to a deficit of US$ 75.8 million recorded in 2006. The inflow of net official transfers was an estimate of US$416 million, a decrease of US$ 33.2 million (7.4 percent) on the previous year. Such inflow reflected the financial assistance that the Royal Government of Cambodia obtained from both multilateral and bilateral development partners, which included a budget support of US$ 21.3 million, food aid of US$ 29.4 million, project aid of US$ 186.6 million and a financing of technical assistance of US$ 179 million. At the same time, net official borrowings (excluding loans from the IMF) were estimated at US$ 173 million, an increase of

41 percent on the preceding year. In 2007, capital inflow in the form of net foreign direct investment was remarkable, reaching US$ 711.2 million. Out of this total, investment in sectors other than the banking sector amounted to US$ 618.1 million, reflecting largely investment in the telecommunication sector, followed by garments and agriculture. Some additional investments were observed in sectors such as hotels and resorts, beverages, packaging, hospital, and shoe production.

សរុបមក ការកើនឡើងនៃគណនីដើមទុននិងហិរញ្ញវត្ថុ គឺមានចំនួនច្រើនជាងតម្រូវការ ដើម្បីផាត់ទាត់នឹងឱនភាពនៃគណនីចរន្ត ។ ជាលទ្ធផល សមតុល្យសរុបមានអតិរេកចំនួន ២៩០លានដុល្លារអាមេរិក នៅឆ្នាំ២០០៧ ។ ទុនបម្រុងផ្លូវការសរុប គឺមានកម្រិតគ្រប់គ្រាន់សម្រាប់ការនាំចូលរយៈពេលបីខែ ។

Overall, the increase in capital and financial accounts was more than the amount needed to offset the current account deficit. As a result, the overall balance was a surplus of US$ 290 million in 2007. The gross official reserves level was sufficient to cover three months of imports.

### ៦. ប្រតិបត្តិការរបស់រដ្ឋាភិបាល (Government operations)

ប្រាក់ចំណូលក្នុងស្រុកបានកើនឡើងចំនួន ២១,៧% គឺកើនឡើងពី ២.៨៩៥,៩ពាន់លានរៀល ក្នុងរយៈពេល ១១ខែដើមឆ្នាំ២០០៦ ទៅ ៣.៥២៥,៨ពាន់លានរៀល ក្នុងរយៈពេល១១ខែដើមឆ្នាំ២០០៧ (១០,១% នៃ GDP) ។ ការកើនឡើងនេះជាចម្បងដោយសារការកើនឡើងនៃពន្ធផ្ទាល់ ដែលបានកើនឡើងដល់ ៤៣២,២ពាន់លានរៀល ជាពិសេសពន្ធលើប្រាក់ចំណេញបានកើនឡើងដល់ ៣៤៨,៤ពាន់លានរៀលក្នុងរយៈពេលដូចគ្នានេះ ។

Domestic revenue increased by 21.7%, from 2,895.9 bn riel during the 11 months Jan-Nov 2006 to 3,525.8 bn riel during Jan-Nov 2007 (10.1% of GDP), due mainly to growth in direct taxes, which rose to 432.2 bn riel, particularly profit tax (348.4 bn riel) during Jan-Nov 2007.

ក្នុងរយៈពេលដូចគ្នានេះដែរ ប្រាក់ចំណាយសរុប បានកើនឡើងចំនួន ១០,៣% គឺកើនឡើងពី ៣.២៩៥,៦ ពាន់លានរៀល ទៅ ៣.៦៣៣,៩ពាន់លានរៀល ដោយចំណាយចរន្តកើនឡើងដល់ ២.២៣៣,៣ ពាន់លានរៀល (៦,៤% នៃ GDP) និងចំណាយមូលធនចំនួន ១.៤០០,៥ពាន់លានរៀល (៤% នៃ GDP ) ។

Total expenditure increased by 10.3% from 3,295.6 bn riel to 3,633.9 bn riel with current expenditure rising to 2,233.3 bn riel (6.4% of GDP) and capital expenditure to 1,400.5 bn riel (4.0% of GDP) during the same period.




សមតុល្យថវិការួម បានកើនឡើងពីឱនភាពចំនួន ៦១៨,៥ពាន់លានរៀល ទៅឱនភាពចំនួន ៣៣៥,២ ពាន់លានរៀល ក្នុងរយៈពេលដូចគ្នានេះដែរ ។

The overall budget balance increased from a deficit of 618.5 bn riel to a deficit of 335.2 bn riel during the same period.

# ប្រវត្តិនៃវិបត្តិ Subprime ការឆក់ឱកាសគេចចំណេញលើអចលនទ្រព្យ និងការធ្លាក់ចុះនៃសេដ្ឋកិច្ច

*អត្ថបទដកស្រង់ពីលោក Fédéric Lordon*

***អត្ថបទនេះប្រែសម្រួល និងសង្ខេបចេញពីអត្ថបទរបស់សេដ្ឋវិទូ លោក Fédéric Lordon ដែលមានចំណងជើងថា "នៅពេលពិភពលោកក្លាយជាចំណាប់ខ្មាំងនៃហិរញ្ញវត្ថុ" ចេញផ្សាយនៅក្នុងខែកញ្ញា ឆ្នាំ២០០៧ នៅសារព័ត៌មាន "ការទូតពិភពលោក (Le Monde Diplomatique)" ។ អត្ថបទនេះបង្ហាញអំពីការជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរមកលើសេដ្ឋកិច្ចពិភពលោក ដោយសារតែការលក់ផ្ទះទៅឱ្យប្រជាជនសហរដ្ឋអាមេរិកដែលពុំមានសាច់ប្រាក់នៅក្នុងដៃ ។***

***នៅរាល់ពេលកើតមានវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ គេតែងសម្គាល់ឃើញថា ធនាគារមានការប្រថុយប្រថានខ្ពស់ និងមើលស្រាលលើហានិភ័យ ហើយមិនយកចិត្តទុកដាក់ស្តាប់ការព្រមានរបស់ធនាគារកណ្តាលនោះទេ ។ ផ្ទុយទៅវិញ នៅពេលវិបត្តិមានសភាពធ្ងន់ធ្ងរឡើង ធនាគារទាំងនោះនឹងប្រកាសសុំជំនួយពីធនាគារកណ្តាល ។***

***អត្ថបទនេះអាចជាមេរៀនមួយសម្រាប់ប្រទេសកម្ពុជា ដែលកំពុងតែជួបប្រទះនូវបញ្ហាដែលធនាគារបង្កើនសម្បៀតឥណទានរបស់ខ្លួនយ៉ាងឆាប់រហ័ស ដោយពុំយកចិត្តទុកដាក់ខ្ពស់លើហានិភ័យចំពោះមុខ ។***

ពីរទសវត្សរ៍កន្លងមកហើយ ដែល Hegel បញ្ជាក់ពីបរាជ័យមកពីការយល់ដឹងពីប្រវត្តិសាស្ត្រមូលធនហិរញ្ញវត្ថុមិនច្បាស់ និងនៅតែដើរតាមគន្លងដដែល នាំឱ្យធ្លាក់ក្នុងវិបត្តិ ។ វិបត្តិហិរញ្ញវត្ថុនៅក្នុងទីផ្សារឥណទាន បច្ចុប្បន្ននេះ ទោះជាប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុថ្មីៗក៏ដោយ នៅតែមានសក្តានុពលនាំមកនូវគ្រោះមហន្តរាយ ដែលចាំបាច់ត្រូវពិនិត្យឡើងវិញលើហានិភ័យនៃទីផ្សារមូលធន ។ ឧស្សាហកម្មហិរញ្ញវត្ថុមិនត្រូវព្រងើយកន្តើយនឹងប្រវត្តិសាស្ត្រ ដែលកើតឡើងដដែលៗ ដោយគិតថា អាជីវកម្មនឹងសម្របសម្រួលដោយខ្លួនឯងទៅតាមទីផ្សារ តាមរយៈលទ្ធផលប្រតិបត្តិការរយៈពេលវែង ។

សេរីភាវូបនីយកម្មហិរញ្ញវត្ថុកន្លងមក ផ្តល់នូវបទពិសោធន៍ផ្សេងៗគ្នា ។ ជាទូទៅមិនហួសពីរយៈពេលបីឆ្នាំម្តងទេ ដែលវិបត្តិធ្ងន់ធ្ងរជាប្រវត្តិសាស្ត្រត្រូវបានកើតឡើង ដូចជា ក្រោយការដួលរលំនៃទីផ្សារហ៊ុនឆ្នាំ១៩៨៧ (ព្រឹត្តិការណ៍ថ្ងៃច័ន្ទ ដ៏ខ្មៅងងឹត Black Monday) មានរឿងអាស្រូវអំពីសញ្ញាប័ណ្ណគ្មានតម្លៃ និងវិបត្តិប្រាក់សន្សំ និងប្រាក់កម្ចីឆ្នាំ១៩៩០ ព្រមទាំងការដួលរលំនៃសញ្ញាប័ណ្ណរបស់សហរដ្ឋអាមេរិកឆ្នាំ១៩៩៤ ។ វិបត្តិហិរញ្ញវត្ថុបានចាប់ផ្តើមនៅអាស៊ីឆ្នាំ១៩៩៧ (ថៃ កូរ៉េ និងហុងកុង) ហើយបន្តដល់ប្រទេសរុស្ស៊ី និងប្រេស៊ីលឆ្នាំ១៩៩៨ និងក្រោយមកទៀតការផ្ទុះឡើងនៃវិបត្តិភាគហ៊ុនព័ត៌មានវិទ្យា (តាមអ៊ិនធើណែត) ឆ្នាំ២០០១ ។

ទោះបីជាហិរញ្ញវត្ថុពិភពលោកមានសមត្ថភាពងើបមកវិញ ហើយខ្លាំងក្លាជាងមុនទៅទៀតក៏ពិតមែន រាល់ពេលដែលទីផ្សារហិរញ្ញវត្ថុមានបញ្ហាកើតឡើង អ្នកដែលរងគ្រោះនោះគឺពលករធម្មតា ។ ការដួលរលំនៃទីផ្សារ

បែបនេះ ជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ធនាគារ ហើយមានផលប៉ះពាល់ដល់ឥណទាន វិនិយោគ កំណើនសេដ្ឋកិច្ច និងការងារ ។

វិបត្តិឥណទាននៅសហរដ្ឋអាមេរិកនាពេលបច្ចុប្បន្ន គឺជាការផ្តល់ឱកាសមួយ ក្នុងការសិក្សាអំពីផលវិបាកធ្ងន់ធ្ងរ ដែលកើតមានឡើងដោយសារការរកស៊ីកេងកម្រៃប្រថុយប្រថានដោយគ្មានក្របខ័ណ្ឌគតិយុត្តគ្រប់គ្រងបានត្រឹមត្រូវ ។ យើងនឹងធ្វើការពិនិត្យមើលតាមដំណាក់កាលចាប់តាំងពីការកេងកម្រៃដោយគ្មានការគ្រប់គ្រងរហូតដល់មានការដួលរលំ ហើយបន្ទាប់មកទៀត គឺការធ្វើអន្តរាគមន៍របស់ធនាគារកណ្តាល ។

### ១- និន្នាការជម្រុញឱ្យមានសកម្មភាព "Ponzi" នៃទីផ្សារ

Hyman Minsky បានបង្ហាញថា ភាពពាក់ព័ន្ធគ្នាទៅវិញទៅមកនៃទីផ្សារហិរញ្ញវត្ថុគឺជាមូលហេតុដ៏ចម្បងនាំមកនូវគ្រោះមហន្តរាយ ។ នៅក្នុងទស្សវត្សរ៍ឆ្នាំ ១៩២0 Charles Ponzi បានបញ្ចុះបញ្ចូលប្រមូលយកប្រាក់សន្សំពីអ្នកសន្សំដោយធានាផ្តល់នូវផលចំណេញខ្ពស់ពីប្រាក់សន្សំទាំងនោះ ។ ផលចំណេញដែលនឹងទទួលបានមិនមែនបានមកពីភាគលាភនោះទេ ប៉ុន្តែ Ponzi បានបញ្ចុះបញ្ចូលបញ្ឆោតយកប្រាក់សន្សំពីបុគ្គលទីពីរ ហើយយកចំណែកខ្លះផ្តល់ជាប្រាក់ចំណេញទៅឱ្យបុគ្គលទីមួយ ។ និរន្តភាពសកម្មភាពនេះចេះតែអាចបន្តទៅបាន នៅរាល់ពេលដែលមានជនរងគ្រោះថ្មីៗចូលរួមបន្តទៀត ។ ក្រៅពីឧទាហរណ៍មួយនេះ សេដ្ឋកិច្ចពពុះដែលពឹងផ្អែកលើលំហូរចូលជាទៀងទាត់នៃមូលធនផ្សេងៗសម្រាប់បន្តដំណើរការទីផ្សារ និងការស្រមើស្រមៃដែលថាខ្លួនជាអ្នកឈ្នះ តែងតែប្រើប្រាស់នូវយន្តការស្រដៀងគ្នានេះ ។ គន្លឹះសំខាន់នៃយន្តការនេះគឺបន្តស្វែងរកអ្នកវិនិយោគថ្មីៗ ហើយនៅពេលឃើញមានអ្នកចាប់ផ្តើម អ្នកផ្សេងទៀតដែលមិនសូវឆ្លាតក៏នាំគ្នាចូលរួមកាន់តែច្រើនឡើងៗ ។

ទីផ្សារអចលនទ្រព្យសហរដ្ឋអាមេរិកមានដំណើរការកើនឡើងជាបន្តបន្ទាប់ ដោយសារក្រុមគ្រួសារបង្ខំចិត្តធ្វើឥណទាននិក្ខេបកាន់តែច្រើន ក្រោយពីទទួលការរងគ្រោះពីការផ្ទុះនូវវិបត្តិអ៊ិនធើណែត ហើយពួកគេស្វែងរកការវិនិយោគថ្មីៗ ។ ប៉ុន្តែ ចំនួនអ្នកខ្ចីដែលមានសមត្ថភាពសងខ្ពស់ កាន់តែខ្សត់ទៅៗ ដែលធ្វើឱ្យឈ្មួញកណ្តាលឈានទៅរកអ្នកខ្ចីដែលមានបញ្ហាចូលទៅកាន់ទីផ្សារកាន់តែច្រើនទើបនាំឱ្យតម្លៃផ្ទះកើនខ្ពស់ឡើងៗ ។

អ្នកខ្ចីនិងឈ្មួញកណ្តាលសន្យាថា ករណីពុំមានលទ្ធភាពសង ពួកគេនឹងលក់អចលនទ្រព្យ ហើយអ្នកខ្ចីទទួលបានផលចំណេញ ចំណែកឈ្មួញកណ្តាលទទួលបានផលកម្រៃជើងសា ។ ពួកគេយល់ថា អ្នកណាក៏មានលទ្ធភាពអាចខ្ចីបានដែរ ដោយសារពួកគេមានជំនឿទុកចិត្តលើការពង្រីកមិនមានដែនកំណត់នៃទីផ្សារ ។ ដូច្នេះ ឥណទានត្រូវបានបើកចំហ ដែលធ្វើឱ្យសកម្មភាពកេងកម្រៃកាន់តែខ្លាំងក្លា ។ ជាលទ្ធផល និក្ខេប Subprime កើតមានឡើង មានន័យថាកម្ចីត្រូវបានផ្តល់ជូនដល់អ្នកខ្ចីដែលគ្មានកំណត់ត្រាឥណទានច្បាស់លាស់ ដែលគេហៅថា កម្ចីទៅកាន់ពពួក "និនចារ" (NINJA-No Income No Job and Asset គ្មានចំណូល គ្មានការធ្វើ និងគ្មានទ្រព្យសម្បត្តិ) ។

## ២- ការវាយតម្លៃមិនគ្រប់គ្រាន់លើហានិភ័យ

ជាទូទៅ គេសន្មតថា ឧស្សាហកម្មហិរញ្ញវត្ថុតែងតែមានទុនបម្រុង និងជំនាញនៅក្នុងការដោះស្រាយនូវហានិភ័យ គឺប្រើប្រាស់នូវឧបករណ៍និស្សន្ទ ។ នៅដើមទស្សវត្សរ៍ឆ្នាំ១៩៩០ ធនាគារបានយល់ឃើញថា អាចបញ្ចូលឥណទានផ្សេងៗទៅក្នុងសញ្ញាប័ណ្ណអាចជួញដូរបាន ។ ដំណើរការបែបនេះ ត្រូវបានគេហៅថា មូលប័ត្រតូបនីយកម្ម ដែលបានន័យថាមូលប័ត្រទាំងនេះអាចត្រូវបានលក់ចេញជាសំណុំទៅកាន់វិនិយោគិន ហើយហានិភ័យឥណទាន ដែលបានបញ្ចូលទៅក្នុងសញ្ញាប័ណ្ណនោះ ក៏ត្រូវបានលុបចេញពីតារាងតុល្យការរបស់ធនាគារដែលចេញផ្សាយផងដែរ ។

ប៉ុន្តែបញ្ហានៅត្រង់ថា ហេតុអ្វីបានជាវិនិយោគិនទាំងនោះព្រមទិញនូវរបស់ដែលធនាគារប្រឹងប្រែងបញ្ចេញចោលទាំងអស់សង្ឃឹមនោះទៅវិញ? ម៉្យាងដោយវិនិយោគិនទិញសញ្ញាប័ណ្ណទាំងនោះនៅក្នុងបរិមាណតិចតួច ហើយម៉្យាងទៀតគេអាចជួញដូរ ឬអាចលក់បន្តបាន ។ មូលប័ត្រដែលបម្លែងចេញពីឥណទានដែលមានហានិភ័យខ្ពស់ប្រភេទនេះ ត្រូវបានគេចំរៀកចេញជាឧបករណ៍ផ្សេងៗ ដែលមានហានិភ័យស្មើៗគ្នា ។ យោងតាមបទពិសោធន៍ និងការគេចវេះពីហានិភ័យ វិនិយោគិនគិតថានឹងអាចធ្វើជម្រើសដ៏ត្រឹមត្រូវ និងមានសុវត្ថិភាពដោយសម្លឹងឃើញថាស្ថាប័នដទៃទៀត ដូចជាមូលនិធិការពារការខាតបង់ (Hedge Funds) និងទទួលបន្តចំណែកឥណទានទាំងនោះ ហើយអាចទទួលផលចំណេញច្រើនផង ប្រសិនបើសភាពការណ៍វិវត្តន៍ទៅតាមការគិតទុក ។

ជាការពិតណាស់ សិទ្ធិនៅក្នុងលំហូរមូលនិធិ និងហានិភ័យនៃការមិនសងដែលភ្ជាប់នៅក្នុងឥណទាន ក៏ត្រូវបានផ្ទេរទៅផ្ទុកក្នុងមូលប័ត្រដែលមានវត្ថុបញ្ចាំជាផ្ទះ (Residential Mortgage-Backed Securities – RMBS) ហើយត្រូវបានផ្ទេរទៅក្នុងចំណោមអ្នកវិនិយោគក្រោយៗជាច្រើន ដោយទទួលហានិភ័យរៀងៗខ្លួន ។ ធនាគារផ្តើមប្រតិបត្តិការក៏មិនត្រូវបានទទួលខុសត្រូវតែឯង លើហានិភ័យនៃការមិនសងនេះដែរ ព្រោះតាមវិធីបំបែកសម្លៀតឥណទានធំមកជាចំណែកតូចៗអាចរំលែកហានិភ័យផងដែរ ។

មូលប័ត្រតូបនីយកម្មហាក់ដូចជាអាចជួយដោះស្រាយបញ្ហាឥណទានដែលមានហានិភ័យខ្ពស់បែបនេះ ដោយបង្កើតឧបករណ៍ពិសេសជាច្រើនដើម្បីជំនួសនូវ RMBSs ។ កាតព្វកិច្ចសងបំណុលមានរបស់បញ្ចាំ (Collateralized Debt Obligations – CDO) គឺជាឧបករណ៍មូលប័ត្រប្រភេទថ្មី ដែលបម្លែងចេញពីមូលប័ត្រដែលបានចេញផ្សាយ ហើយអាចបម្លែងបន្តទៀតពីសំណុំ RMBS ទៅជាមូលប័ត្រផ្សេងៗ ។ មូលប័ត្រវិនិយោគដំបូងអាចទទួលរងហានិភ័យនៃការមិនទូទាត់សងរបស់អ្នកកាន់ ពី ២០ ទៅ ៣០ ភាគរយដំបូងនៃកម្ចីនិក្ខេបដើម ។ មូលប័ត្រអន្តរកាល និងមូលប័ត្រចុងក្រោយគឺមូលប័ត្រលើទ្រព្យម្ចាស់ ដែលទទួលរងគ្រោះមុនគេក្នុងករណីមិនសង មូលប័ត្រនេះត្រូវបានទីផ្សារហៅថា ជាសំណល់ជាតិពុល (Toxic Waste) ដែលសមស្របទៅតាមផលិតផល CDO ដែលបម្លែងចេញពីមូលប័ត្រមានហានិភ័យខ្ពស់ជាងគេ RMBSs ដែលត្រូវបានបម្លែងចេញពីសម្លៀតឥណទានដើម ។ នៅពេលដែលទីផ្សារអចលនវត្ថុកំពុងតែពុះកញ្ជ្រោល ហើយក្រុមគ្រួសារបន្តធ្វើការទូទាត់សង ជាទូទៅតែងមានអ្នកទទួលទិញបន្ត ។

មូលនិធិការពារការខាតបង់ ដែលជាទូទៅមានលទ្ធភាពប្រមូលប្រាក់ក្នុងអត្រាការប្រាក់ទាប តែងតែត្រូវបានវិនិយោគលើមូលប័ត្រដែលមានហានិភ័យខ្ពស់ ដោយសារមូលប័ត្រទាំងនេះអាចលក់បន្តបានដោយសេរីនៅក្នុងទីផ្សារដែលសកម្មបំផុត ។ គម្លាតប្រាក់ចំណេញខ្ពស់ អាចប្រែក្លាយសំណល់ជាតិពុលឱ្យទៅជាមាសបាន ហើយដែលប្រាក់ចំណេញនេះបានលាក់កំបាំងនូវហានិភ័យដែលគេតែងតែព្រងើយកន្តើយ ព្រោះភ័យខ្លាចថា នឹងសម្លាប់សត្វក្ងានដែលមានពងជាមាស ។ ទន្ទឹមនឹងនេះ ឈ្មួញទិញទិក្ខេបនៅតែបន្តបន្ថែមអ្នកទិញថ្មីៗ ។

### ៣- ភាពងាយរងគ្រោះ និងបរាជ័យជារចនាសម្ព័ន្ធ

ការស្រមើស្រមៃថាមូលប័ត្រូបនីយកម្ម អាចបម្លែងហានិភ័យឱ្យរលាយអស់ បានបង្កឱ្យមានឥរិយាបថតក់ក្រហល់ពីសំណាក់អ្នកឱ្យខ្ចី ដែលជឿថាខ្លួនបានរំដោះចេញសម្ពៀតឥណទានអាក្រក់ ហើយនឹងអាចធ្វើអ្វីគ្រប់យ៉ាង ។ ចំណែកឯសាច់ប្រាក់ងាយស្រួលដែលមាននៅក្នុងទីផ្សារឧបករណ៍និស្សន្ទ បានជំរុញឱ្យមូលនិធិដែលមានការធានាចាប់យកនូវ CDOs ដ៏មានប្រាក់ចំណេញខ្ពស់ តែហានិភ័យក៏ខ្ពស់ផងដែរ ហើយនាំឱ្យមានកំណើនអំពីបរិមាណមិនអាចត្រួតត្រាបាននោះជាស្ថានភាពដ៏គ្រោះថ្នាក់ ។

ភាពផុយស្រួយ និងងាយរងគ្រោះបែបនេះ សំបកក្រៅហាក់ដូចជាពុំមានអ្វីគួរឱ្យចាប់អារម្មណ៍ ។ ការតម្លើងអត្រាការប្រាក់ ០,២៥ ភាគរយរបស់ធនាគារសហព័ន្ធសហរដ្ឋអាមេរិកក៏ដូចជាគ្មានអ្វីគួរឱ្យកត់សម្គាល់ផងដែរ ប៉ុន្តែនៅខែសីហា ឆ្នាំ២០០៧ សារព័ត៌មាន New York Times បានរាយការណ៍ថា ស្ត្រីម្នាក់ពុំមានលទ្ធភាពបង់ប្រាក់សង ដោយសារអត្រានិក្ខេប (Mortgage) របស់គាត់បានកើនឡើងពី ៦,៣ ភាគរយនៅក្នុងឆ្នាំ២០០៥ ដល់ ១១,២៥ភាគរយ នៅក្នុងឆ្នាំ២០០៧ ដែលធ្វើឱ្យការទូទាត់ប្រចាំខែរបស់គាត់ កើនពី ៤១៤ដុល្លារអាមេរិក ដល់ ៦៩១ដុល្លារអាមេរិក ។ ស្ត្រីម្នាក់នេះស្ថិតនៅក្នុងចំណោម ១៤ភាគរយនៃអ្នកខ្ចី Subprime ដែលពុំមានលទ្ធភាពសងនៅក្នុងត្រីមាសដំបូងនៃឆ្នាំ ២០០៧ ។

ការកើនឡើងទោះជាតិចតួចក្តីនៃអត្រាការប្រាក់របស់ធនាគារកណ្តាលជះឥទ្ធិពលពីរយ៉ាង ។ តម្លៃផ្ទះមានការធ្លាក់ចុះ លើកលែងតែចំពោះអ្នកទិញថ្មីៗនៃទីផ្សារផ្ទះសម្បែង ។ អ្នកទិញអចលនទ្រព្យមុនៗកំពុងតែប្រឈមមុខនឹងការបាត់លទ្ធភាពក្នុងការទូទាត់សងដោយសារការខាតបង់នូវតម្លៃហិរញ្ញវត្ថុនៃទ្រព្យសម្បត្តិ ហើយបញ្ហានេះបានរាលដាលដល់គ្រប់ៗគ្នា ។

នៅពេលមានវិបត្តិហិរញ្ញវត្ថុ ជានិច្ចកាលមានស្ថាប័នជំនាញមួយដែលដួលរលំ និងផ្តល់សញ្ញាជាទូទៅ ។ ករណីវិបត្តិ Subprime នេះ បញ្ហាទាំងសងខាង ទាំងអ្នកខ្ចី និងអ្នកឱ្យខ្ចី នឹងធ្វើឱ្យទីផ្សារធ្លាក់ចុះដល់ដី ។ ធនាគារវិនិយោគ Bear Stearns របស់សហរដ្ឋអាមេរិកត្រូវបង្ខំឱ្យបញ្ឈប់មូលនិធិពីរដែលធ្លាប់មានថាមភាពខ្លាំងក្លា (ហួសហេតុ) ក្រោយពីធនាគារនេះទទួលរងគ្រោះដោយ CDOs ។

អ្វីដែលគួរឱ្យភ្ញាក់ផ្អើលជាងនេះទៅទៀត គឺនៅដើមខែសីហា ស្ថាប័នអ្នកឱ្យខ្ចី ឈ្មោះ American Home Mortgage បានស្វែងរកការការពារតាមជំពូកទី១១ នៃច្បាប់ក្ស័យធន ដើម្បីអាចបន្តអាជីវកម្មបានដោយបន្ថយបុគ្គលិកនិងពិនិត្យឡើងវិញនូវប្រាក់បំណាច់របស់និយោជិត ។

## ៤- ការវាយតម្លៃឡើងវិញនូវមហន្តរាយនៃហានិភ័យ

កាន់តែមានការព្រួយបារម្ភទៀតនោះ គឺសំណល់ជាតិពុលនៃសញ្ញាប័ណ្ណ បានមានរឿងមិនល្អរួចទៅហើយ ហើយមានការសង្ស័យថា សូម្បីតែការវិនិយោគសញ្ញាប័ណ្ណ CDO ក៏មិនអាចជឿទុកចិត្តបានដែរ ។ តើឧស្សាហកម្មនេះឈានទៅធ្វើការវិនិច្ឆ័យដ៏មានកំហុសបែបនេះដោយរបៀបណា? បញ្ហាគឺជាភាពស្មុគស្មាញនៃការវាយតម្លៃឧបករណ៍និស្សន្ទ ។ អង្គភាពធ្វើចំណាត់ថ្នាក់ឥណទាន បានទទួលធ្វើការវាយតម្លៃលើមូលប័ត្រ CDO និង RMBS យ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ប៉ុន្តែ ការវាយតម្លៃនេះមិនមែនធ្វើឡើងដោយការស្មោះត្រង់ចំពោះភារកិច្ចរបស់ខ្លួននោះទេ អង្គភាពទាំងនោះលំអៀងចំពោះកម្រៃច្រើន ដែលទទួលបានពីការវាយតម្លៃ ដោយសារស្ថាប័នហិរញ្ញវត្ថុចេញផ្សាយនូវមូលប័ត្រយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ នៅក្នុងឆ្នាំ២០០៦ អង្គភាពធ្វើចំណាត់ថ្នាក់ឥណទាន Moody's រកប្រាក់ចំណូលបាន ៤០ភាគរយ នៃចំណូលសរុប ពីការវាយតម្លៃលើផលិតផលដែលបានកែច្នៃពីឥណទានដែលមានហានិភ័យខ្ពស់ ។ នេះបង្ហាញពីការលើកទឹកចិត្ត ឱ្យមានការបង្កើតនូវផលិតផលថ្មីៗជំរុញនូវអាជីវកម្មថ្មីៗបន្ថែមទៀត ។

